**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No.17PR-21/EoJ 07 May 2021

## Handover Ceremony of 35 Ambulances Donated by the Government of Japan

As a part of efforts of the Government of Japan to counter Novel Coronavirus infection worldwide, it has decided to provide the Kingdom of Cambodia with 35 ambulances.The Handover Ceremony was held on May 7, 2021 at Ministry of Health Central Medical Storage (CMS) presided over by H.E.Dr.Youk Sambath, Secretary of State, Minsitry of Health and Mr.KARIMATA Atsushi , Minister and Deputy Chief of Mission of the Embassy of Japan to the Kingdom of Cambodia.

This assistance is based on the cooperation measures put in place with ASEAN countries that were announced by former Prime Minister ABE Shinzo at the Special ASEAN Plus Three Summit held in April last year. The initiative is one of many employed by the Government of Japan to confront COVID-19 on a global scale. So far, in response to a request from the Royal Government of Cambodia, Japan has supplied medical equipment such as ambulances, X-ray inspection equipment, ultrasound diagnostic equipment, oxygen generators and ICU beds to Cambodia.

Japan will continue to cooperate with the Royal Government of Cambodia to provide necessary equipment. We hope that these supplies will be helpful for the Cambodian healthcare professionals who are working so hard to fight COVID-19.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161, fax: 023-214-330*
*Email: eco.jpn@.pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខៈ 17PR-21/EoJ ថ្ងៃទី០៧ខែឧសភា ឆ្នាំ២០២១

## ពិធីប្រគល់ទទួលរថយន្តគិលានសង្គ្រោះ ៣៥គ្រឿងដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុន

ជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងនឹង ការឆ្លងវីរុសកូរ៉ូណាប្រភេទថ្មី នៅលើសកលលោក រដ្ឋាភិបាលជប៉ុនបានសម្រេចផ្តល់រថយន្តគិលានសង្គ្រោះចំនួន៣៥គ្រឿងជូនដល់ព្រះរាជាណាចក្រកម្ពុជា។ ពិធីប្រគល់ទទួលត្រូវបានប្រារព្ធឡើងកាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ នៅឃ្លាំងឱសថកណ្តាលនៃក្រសួងសុខាភិបាល ក្រោមវត្តមានរបស់លោកជំទាវវេជ្ជបណ្ឌិត យក់ សម្បត្តិ រដ្ឋលេខាធិការក្រសួងសុខាភិបាលនិង លោក ការិម៉ាតា អាត្សឹស៊ី ឧបទូតនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា។

ជំនួយនេះគឺផ្អែកលើវិធានការណ៍កិច្ចសហប្រតិបត្តិការដែលបានដាក់ចេញជាមួយបណ្តាប្រទេសអាស៊ានដែលត្រូវបានប្រកាសដោយលោកអតីតនាយករដ្ឋមន្ត្រីស៊ីនហ្សូ អាបិនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេសកាលពីខែមេសាឆ្នាំមុន។ គំនិតផ្តួចផ្តើមនេះគឺជាផ្នែកមួយនៃការងារជាច្រើនរបស់រដ្ឋាភិបាលជប៉ុនក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ លើកម្រិតសកល។ រហូតមកដល់ពេលនេះ ឆ្លើយតបនឹងការស្នើរសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ជប៉ុនបានផ្តត់ផ្គង់គ្រឿងបរិក្ខារវេជ្ជសាស្ត្រដូចជារថយន្តគិលានសង្គ្រោះ ឧបករណ៍ត្រួតពិនិត្យកាំរស្មីអ៊ិច ឧបករណ៍ធ្វើរោគវិនិច្ឆ័យអ៊ុលត្រាសោន ឧបករណ៍ផលិតអុកស៊ីសែន និងគ្រែសង្គ្រោះបន្ទាន់ជូនដល់កម្ពុជា។

ប្រទេសជប៉ុននឹងបន្តកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់នូវឧបករណ៍ចាំបាច់។ យើងសង្ឃឹមថាការផ្គត់ផ្គង់ទាំងនេះនឹងអាចជួយដល់ភាគីពាក់ព័ន្ធផ្នែកសុខាភិបាលនៅកម្ពុជាដែលកំពុងប្រយុទ្ធប្រឆាំងជាមួយនឹងជំងឺកូវីដ១៩។

---


*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 210 384*

*Email: eco.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*


TOYOTA


TOYOTA
TOYOTA